ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៩ សហវ

# សារាចរណែនាំ
## ស្តីពីការបិទបញ្ជីចំណូល ចំណាយ
## និងធ្វើរបាយការណ៍បូកសរុបទូទាត់ថវិកាខេត្ត ក្រុង ឆ្នាំ ២០០៥

យោងមាត្រា ១២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ និងប្រការ ៣២ ប្រការ ៣៣ នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ បានកំណត់ថា ថវិកាខេត្ត ក្រុងត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិទូទៅ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដូច្នេះ ដើម្បីធានាអោយការបិទបញ្ជីចំណូល ចំណាយ និងធ្វើរបាយការណ៍បូកសរុបសំរេចទូទាត់ថវិកាខេត្ត ក្រុងប្រចាំឆ្នាំ ២០០៥ ប្រព្រឹត្តទៅបានត្រឹមត្រូវ និងទាន់ពេលវេលានោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេសដូចតទៅ ៖

១. អភិបាលខេត្ត ក្រុងដែលជាអាណាប័កដើមខ្សែ ត្រូវខិតខំជំរុញចំណូលសារពើពន្ធ និងប្រមូលចំណូលមិនមែនសារពើពន្ធ ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន បង់ចូលថវិកាខេត្ត ក្រុងទាំងអស់យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ។ ប្រសិនបើមានការយឺតយ៉ាវក្រោយថ្ងៃកំណត់នេះ រតនាគារខេត្ត ក្រុង ត្រូវកត់ត្រាចូលជាចំណូលថវិកាខេត្ត ក្រុងសំរាប់ឆ្នាំ ២០០៦ ។

២. ការស្នើសុំថវិកាឧបត្ថម្ភតុល្យភាព ក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុងទាំងអស់ ត្រូវបញ្ជូនសំណុំលិខិតស្នើ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៥ ។

៣. ការធ្វើនិយ័តភាពឥណទានផ្ទៃក្នុងជំពូក ក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុងទាំងអស់ ត្រូវបញ្ជូនសំណុំលិខិតស្នើសុំមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ក្រុង យ៉ាងយូរត្រឹមថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៥ ។ ដោយឡែកការធ្វើនិយ័តភាពឥណទានដែលពាក់ព័ន្ធដល់ការសុំអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុងទាំងអស់ត្រូវបញ្ជូនសំណុំលិខិតស្នើសុំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៥ ។

៤. រតនាគារខេត្ត ក្រុង ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់នៅម៉ោង ១៧ និង៣០នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ។ ដូច្នេះក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុង ត្រូវប្រញាប់ប្រមូលសក្ខីប័ត្រ និង លិខិតយុត្តិការ ដើម្បីធ្វើអាណត្តិ (ទាំងអាណត្តិទូទាត់ត្រង់ ទាំងអាណត្តិទូទាត់រដ្ឋទេយ្យបុរេប្រទាន) បញ្ជូនទៅឆ្លងទិដ្ឋាការមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ រួចដាក់ជូនឯកឧត្តមអភិបាលខេត្ត ក្រុងចុះហត្ថលេខា និង បញ្ជូនទៅរតនាគារខេត្ត ក្រុងអោយបានមុនម៉ោង ១៧ និង៣០នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ។

៥. នៅចុងថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ រតនាគារខេត្ត ក្រុង ត្រូវដំណើរការផ្ទេរសមតុល្យគណនីចំណូល ចំណាយរបស់សាលាខេត្ត ក្រុង ចូលទៅក្នុងគណនីលទ្ធផលនៃការិយបរិច្ឆេទ ។ ប្រសិនបើមានអតិរេក នោះសាលាខេត្ត ក្រុងត្រូវធ្វើសលាកប័ត្រចំណូលបង់ចូលថវិការដ្ឋឆ្នាំ ២០០៥ ជាបន្ទាន់ ក្នុងករណីមានការយឺតយ៉ាវស្ថិតនៅចន្លោះពីថ្ងៃទី ០១ ខែ មករា ដល់ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៦ នោះ កាលបរិច្ឆេទនៃការបង់ក៏ត្រូវចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ដែរ ។ ផ្ទុយទៅវិញ ប្រសិនបើហួសកាលកំណត់ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៦ ហើយ សាលាខេត្ត ក្រុង នៅតែពុំទាន់បានបង់ទេនោះ គឺរតនាគារខេត្ត ក្រុងត្រូវម្ចាស់ការផ្ទេរដោយស្វ័យប្រវត្តិចូលជាចំណូលថវិការដ្ឋ ហើយត្រូវជូនដំណឹងទៅសាលាខេត្ត ក្រុងអោយបានជ្រាប ។ កាលបរិច្ឆេទនៃការផ្ទេរនេះ ក៏ត្រូវចាត់ទុកថាជាកិច្ចប្រតិបត្តិការថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ដែរ ។

៦. កិច្ចប្រតិបត្តិការនិយ័តកម្មបរិយកម្មរបស់រតនាគារ សំរាប់ថវិកាខេត្ត ក្រុង ឆ្នាំ ២០០៥ ត្រូវបន្តរហូតដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៦ ។ កិច្ចប្រតិបត្តិការនេះ ត្រូវបានពិនិត្យកត់ត្រាជាលេខទាបន្ថែមនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលទាក់ទងទៅនឹង ៖

- ការកត់ត្រាជាស្ថាពរនៃចំណូល ឬនៃចំណាយ ដែលបានពិនិត្យកត់ត្រាជាលេខទាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ជាអាទិ៍ ចូលគណនីកត់ត្រាបណ្តោះអាសន្ន ។
- អាណត្តិនិយ័តការូបនីយកម្ម ដែលទាក់ទងដល់ចំណាយដែលបានទូទាត់ដោយរដ្ឋទេយ្យបុរេប្រទានមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ។
- ការកែប្រែលេខទាខុស ។

៧. ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៦ តទៅ រាល់កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាខេត្ត ក្រុងឆ្នាំថ្មី ត្រូវកត់ត្រាចូលក្នុងគណនីថវិកាខេត្ត ក្រុងឆ្នាំ ២០០៦ ។

៨. ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៦ រតនាគារខេត្ត ក្រុង និងក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុង ត្រូវដំណើរការបូកសរុបនិងផ្ទៀងផ្ទាត់ពីការអនុវត្តចំណូល ចំណាយថវិកាខេត្ត ក្រុង ឆ្នាំ ២០០៥ ដោយរតនាគារខេត្ត ក្រុងត្រូវបង្កើតតារាងតុល្យភាពគណនីប្រចាំឆ្នាំ និងក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុងត្រូវធ្វើតារាងបូកសរុបចំណូល ចំណាយថវិកាខេត្ត ក្រុងតាមមាតិកាថវិកា រួចធ្វើកំណត់បង្ហាញដាក់ជូនឯកឧត្តមអភិបាលខេត្ត ក្រុងពិនិត្យសំរេចនិងចុះហត្ថលេខា។ អភិបាលខេត្ត ក្រុងត្រូវធ្វើលិខិត

បញ្ជូនតារាងតុល្យភាពគណនីប្រចាំឆ្នាំ តារាងបូកសរុបចំណូល ចំណាយ និងកំណត់បង្ហាញខាងលើទៅក្រសួងមហាផ្ទៃចំនួន ០១ច្បាប់ និងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ០២ច្បាប់ អោយបានមុនថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៦ ដើម្បីនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការបូកសរុប និងរៀបចំនូវរបាយការណ៍សំរេចទូទាត់ថវិកាខេត្ត ក្រុងរួមមួយ ដើម្បីដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។

អភិបាលខេត្ត ក្រុង ត្រូវយកចិត្តទុកដាក់អនុវត្តអោយបានតាមការកំណត់ដូចខាងលើ ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានលទ្ធភាពធ្វើការបូកសរុប រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេច និងរដ្ឋសភា ព្រឹទ្ធសភាពិនិត្យអនុម័តអោយបានទាន់ពេលវេលា ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០០៥

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចំលងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ធនាគារជាតិ
- សាលាខេត្ត ក្រុង
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ក្រុង
- ធនាគារខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

លេខកូដ............

# តារាងបូកសរុបចំណូលថវិកាខេត្ត ក្រុង
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥

តារាងឧបសម្ព័ន្ធ១

| ជំពូក ប្រការ កថាខណ្ឌ វាក្យខណ្ឌ | បរិយាយ ចំណាត់ថ្នាក់ចំណូល ១ | ច្បាប់ ហិរញ្ញវត្ថុដើមឆ្នាំ ២ | អនុវត្ត ជាក់ស្តែង ៣ | សមាមាត្រ ប្រៀបធៀប ៤=៣ / ២ | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |
| | សរុបរួម | | | | |

| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា |
|---|---|---|---|
| អភិបាលខេត្ត ក្រុង | ប្រធានរតនាគារខេត្ត ក្រុង | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អ្នកធ្វើតារាង |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

លេខកូដ............

## តារាងបូកសរុបចំណាយថវិកាខេត្ត ក្រុង

## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥

តារាងឧបសម្ព័ន្ធ២

| ជំពូក | ប្រការ | កថាខណ្ឌ | វិភាគខណ្ឌ | បរិយាយ<br>ចំណាត់ថ្នាក់ចំណាយ<br>១ | ច្បាប់<br>ហិរញ្ញវត្ថុដើមឆ្នាំ<br>២ | ឥណទាន<br>អនុញ្ញាត<br>៣ | អនុវត្ត<br>ជាក់ស្តែង<br>៤ | សមាមាត្រ<br>ប្រៀបធៀប<br>៥-៤ / ៣ | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | | | | | |

| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា |
|---|---|---|---|
| អភិបាលខេត្ត ក្រុង | ប្រធានរតនាគារខេត្ត ក្រុង | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អ្នកធ្វើតារាង |